BMI0100

# សម្ភាសន៍ជាមួយឈ្មោះ សុ បិ ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ មេកងធំចល័ត

## សព្វថ្ងៃរស់នៅភូមិយាងវៀន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:២៨:៤២

## ១១ទំព័រ

ប៊ុនថន : ដំបូងអ៊ំឈ្មោះអីដែរ?

បិៈ សុ បិ ។

ប៊ុនថន : សុ?

បិៈ សុ បិ ។

ប៊ុនថន : សុ ភិ?

បិៈ សុ បិ ។

ប៊ុនថន : សុ បិ?

បិៈ បាទ!

ប៊ុនថន : អ៊ំអាយុប៉ុន្មានហើយ?

បិៈ ៥៦ហើយ ។

ប៊ុនថន : អ៊ំស្រុកកំណើតនៅណាដែរ?

បិៈ នៅយាមវេន ។

ប៊ុនថន : នៅភូមិយាមវេន ឃុំផ្គាំ ។

បិៈ បាទ!

ប៊ុនថន : អ៊ំពីដើមរៀនដល់ណាដែរ?

បិៈ ខ្ញុំមិនបានរៀនទេ ខ្ញុំបួសបាន៣វស្សា ។

ប៊ុនថន : បួសនៅវត្តណាដែរ?

បិៈ បួសនៅផ្គាំ ។

ប៊ុនថន : វត្តផ្គាំ?

បិៈ បាទ!

ប៊ុនថន ៖ អ៊ំបួសហ្នឹងបួសនៅសម័យ លន់ នល់?

បិៈ សម័យ លន់ នល់ ។

ប៊ុនថន ៖ ក្រោយពីសឹកអ៊ំទៅណា?

បិៈ ក្រោយពីសឹកមក សឹកសម័យ៣ឆ្នាំ គេជ្រើកពួកខ្ញុំហ្នឹង លោកវត្តគោកខ្ពស់ ។

ប៊ុនថន ៖ ខ្មែរក្រហមជ្រើក?

បិៈ ខ្មែរក្រហមជ្រើក ។

ប៊ុនថន ៖ កាលហ្នឹងលោកច្រើនអន្កទេ?

បិៈ ច្រើន ចាប់ពីស្វាយមកនេះទាំងអស់ តាំងពីវត្តសឹង មកនេះទាំងអស់ ទាំងខ្ទប មកជុំគ្នានៅ វត្តគោកខ្ពស់នេះ ។

ប៊ុនថន ៖ ហ្នឹងសឹកហើយឲ្យទៅជុំគ្នានៅនោះ?

បិៈ បាទ! ទេ ប្រមូលលោកទាំងសង្ឃហ្នឹងក្នុងវត្តគោកខ្ពស់ ដល់ប្រមូលបានជុំនៅទាំងអស់បាន ជ្រើក ។

ប៊ុនថន ៖ អីចឹងទៅពីវត្តផ្ទាំនេះប៉ុន្មានអន្ក?

បិៈ គេជគុណច្រើនណាស់កាលនោះ សាមសិបអន្កជាង លោកពេញ... មានកុដិឯណាវត្ត ទើបតែធ្វើបានកុដិ២ខ្នង ។

ប៊ុនថន ៖ សង្ឃរាជកាលហ្នឹងឈ្មោះអីដែរ?

បិៈ ប្រាំង លេញ ។

ប៊ុនថន ៖ អ៊ំទៅជុំនៅវត្តហ្នឹងហើយ វត្តអីវិញ?

បិៈ វត្តគោកខ្ពស់ ។

ប៊ុនថន ៖ នៅក្នុងភូមិ ឃុំអីដែរ?

បិៈ ដើមឡើយឃុំ សព្វថ្ងៃគេបញ្ចូលទៅឃុំគោកកបិន ។

ប៊ុនថន ៖ កាលហ្នឹងទៅជុំគ្នា គេណែនាំម៉េចទៅ?

បិៈ គ្មានណែនាំទេ គ្មានសួរអីទេ ទៅគ្រូសង្ឃរាជនឹងវត្តខ្ញុំនេះ គាត់ឋានៈគាត់ប៉ុណ្ណឹងហើយ គាត់ វិភាគដូចមិនស្រួល ដល់ហើយនាំកូនចៅលោកសឹកអស់មួយវត្តទៅ ។

ប៊ុនថន ៖ សឹកនៅហ្នឹង ចុះវត្តផ្សេងៗទៀត?

បិៈ វត្តផ្សេងៗ គេសឹកបណ្តើរៗ តាមលោកចៅអធិការវត្តគេ ខាងថ្មពួក ឡៅ អើយ គាត់សឹក ក្នុងវត្តគោកខ្ពស់ដែរ ។

ប៊ុនថន : មានសង្ឃខ្លះគវ៉ា ដូចសង្ឃរាជអី?

បិៈ មិនមានទេ គ្មានឯណាបើគេអាជ្ញាសឹកអីចឹងម៉េចហ៊ាននិយាយ ម៉េចហ៊ាននិយាយកាលនោះ ដឹងតែគេអីចឹង ខ្លាចដែរ ។

ប៊ុនថន : តែអត់បានប្រជុំណែនាំថាត្រូវ?

បិៈ គ្មានទេ ។

ប៊ុនថន : ក្រោយពីផ្សឹកហើយអ៊ំទៅណាវិញ?

បិៈ ខ្ញុំនៅធ្វើស្រែហ្នឹងភូមិហ្នឹងឯង បង្កបង្កើតផលហ្នឹងគេ ។

ប៊ុនថន : ចុះឪពុកម្តាយអ៊ំនៅណា?

បិៈ ឪពុកម្តាយខ្ញុំនៅនេះ សព្វថ្ងៃគាត់ស្លាប់ចោលអស់ហើយ ម្តាយខ្ញុំស្លាប់តាំងពីសម័យ តាំងពីខ្ញុំនៅតូចម៉្លេះ មុនរដ្ឋប្រហារទៀត ។

ប៊ុនថន : ចុះឪពុក?

បិៈ ឪពុកខ្ញុំទើបតែស្លាប់បានប៉ុន្មានឆ្នាំនេះឯង ។

ប៊ុនថន : អ៊ំមកបង្កបង្កើនផលនៅភូមិនេះ ធ្វើអីខ្លះ?

បិៈ ខ្ញុំនោះ មុនដំបូងគេឲ្យធ្វើមេក្រុមខាងយុវជនហ្នឹង ដល់យូរៗឲ្យខ្ញុំធ្វើបញ្ជីទៅ គេឲ្យឡើងធ្វើ មេកងតូច ធ្វើបញ្ជីឲ្យគេ ធ្វើយោបល់ ឲ្យធ្វើមេកងតូច រាយមកធ្វើមេកងធំ ប៉ុណ្ណឹងឯង ចប់ត្រឹមមេកងធំក៏ខ្ញុំរត់ចុះស្រុកបណ្តោយ ខ្ញុំរត់ចូលស្រុកឡើង១ឆ្នាំ ។

ប៊ុនថន : មេកងតូចដូចអ៊ំម៉ិញថាទៅទំនប់ណា?

បិៈ មេកងតូចខ្ញុំធ្វើជាមួយ បងថាន ហ្នឹងឯង ទៅអាងត្រពាំងថ្ម មើលអាងត្រពាំងថ្មរួចទៅ មើលអាងផ្តាំ មើលអាងផ្តាំរួចខ្ញុំរត់ ។

ប៊ុនថន : អាងត្រពាំងថ្មហ្នឹងអ៊ំនាំកំលាំងទៅពីនេះច្រើនទេ?

បិៈ អត់ទេ ពួកខ្ញុំ៣ភូមិហ្នឹងឯង ភូមិយាមវេន ភូមិ... ភូមិអំពិលហ្នឹងឯង មិនមែនខ្ញុំក្តាប់ទាំង អស់ទេ ។

ប៊ុនថន : អ៊ំក្តាប់ទាំងអស់៣ភូមិ?

បិៈ ខ្ញុំក្តាប់តែ៣ភូមិហ្នឹងឯង ។

ប៊ុនថន : កំលាំងទៅពីហ្នឹង៣ភូមិហ្នឹង ប៉ុន្មាននាក់?

បិៈ ៣ភូមិហ្នឹងយុវជនវា៩០នាក់ ១កងតូចវា៣០នាក់ ៣កងវា៩០ ។

ប៊ុនថន ៈ អ៊ីដឹកនាំទៅ ហើយសហករណ៍ផ្សេងៗគេទៅ?

បិៈ សហករណ៍ផ្សេងគេទៅដូចតែគ្នាហ្នឹង គេទៅជាមួយគ្នា ខ្ញុំនាំទៅហើយគេមានប្រធានសហករណ៍គេក្តាប់ពីលើខ្ញុំទៀត ខ្ញុំគ្រាន់តែវង់គេជំនួយខាងយុវជន ។

ប៊ុនថន ៈ ប្រធានសហករណ៍ឈ្មោះអី?

បិៈ ប្រធានសហករណ៍ឈ្មោះប៊ុ មឿន ។

ប៊ុនថន ៈ គាត់អ្នកភូមិហ្នឹងដែរអ៊ំ?

បិៈ ភូមិបត់ ។

ប៊ុនថន ៈ ឃុំ?

បិៈ មិនដឹងឃុំអីទេសម័យនោះ ។

ប៊ុនថន ៈ អ៊ំនាំកំលាំងទៅ៩០នាក់ហ្នឹង ទៅធ្វើយូរទេត្រពាំងថ្មហ្នឹង?

បិៈ ទៅបានប៉ុន្មានខែ ទៅបាន២ខែរួចអាងត្រពាំងថ្មក៏ឲ្យខ្ញុំមកអាងផ្តៅវិញ ។

ប៊ុនថន ៈ នៅហ្នឹងហូបចុកអី ខាងប្រធានក្រុម ប្រធានកង អ្នកដោះស្រាយ?

បិៈ កាលពួកខ្ញុំធ្វើនៅហូបបាយរីងទេ បាយរីងក្នុង១ថ្ងៃ៣ដង មុនដំបូងពីព្រឹកចាប់ឲ្យចុងភៅដាំបាយ ហ្នឹងត្រីងៀតអាំង ដល់បាយថ្ងៃគេស្ងួរ កាលពួកខ្ញុំលើកបានស្ងួរ ដល ដឹងហើយ ១ថ្ងៃ៣ដង ដល់ចុងក្រោយល្ងាចក៏បាយរីងទៀត ដល់គេទៅលើកព្រែកឯណានោះខ្ញុំមិនដឹងទេខ្ញុំរត់ផុតហើយ ។

ប៊ុនថន ៈ ហ្នឹងហូបបាន៣ដង?

បិៈ ១ថ្ងៃ៣ដង

ប៊ុនថន ៈ អីចឹងហូបតាមកងដែលអ៊ំគ្រប់គ្រងហ្នឹង ដូចថា៩០នាក់ ហូប៩០នាក់ គេកងផ្សេងហូបផ្សេងទៅ?

បិៈ គេហូបផ្សេង ពួកខ្ញុំនៅផ្សេង ។

ប៊ុនថន ៈ អ្នកដែលគ្រប់គ្រងនៅហ្នឹងពីណាវិញ អាងត្រពាំងថ្មហ្នឹង?

បិៈ មិនស្គាល់ទេ ព្រោះខ្ញុំនៅក្រោមគេ មើលខ្មោចតា មឿន ហ្នឹងឯង ដែលនៅលាយបត់ ។

ប៊ុនថន ៈ អ៊ំនៅហ្នឹងលើកទាល់តែហើយ បានមកវិញ?

បិៈ ខ្ញុំលើកអាងរួចខ្ញុំមកវិញ គេឲ្យមក អាងផ្តៅ ក្នុងចំណុះឃុំផ្តាំមកលើកអាងផ្តាំនេះវិញ ។

ប៊ុនថន ៈ អីចឹងមកកំលាំងទាំងអស់ ឬក៏មាននៅនោះខ្លះ ឬមួយទៅណា?

បិៈ នៅនេះខ្លះ ពួកខ្ញុំមកមួយចំនួន ។

ប៊ុនថន ៖ មកប៉ុន្មាននាក់អ៊ំ?

បិៈ មកប្រហែលខាងពួកខ្ញុំ៣ភូមិ មកប្រហែល៥០នាក់ ។

ប៊ុនថន ៖ អ៊ីចឹងនៅ៤០នាក់នៅនោះ?

បិៈ បាទ!

ប៊ុនថន ៖ ប៉ុន្តែអ្នកនោះនៅ ដល់ក្រោយមកមានត្រឡប់មកភូមិវិញទេ?

បិៈ មក មកវិញអស់...។

ប៊ុនថន ៖ អត់មានបាត់ទៅណាទេ?

បិៈ អត់មានទេ ភូមិខ្ញុំមកអស់ ខាងមោយក៏មកអស់ អំពិលក៏មកអស់ ។

ប៊ុនថន ៖ អ៊ំមកធ្វើនៅអាងថ្កាំ អ៊ំនៅក្តាប់កងដដែរ?

បិៈ ខ្ញុំនៅក្តាប់កងដដែរ ។

ប៊ុនថន ៖ ម៉េចទៀតទៅអ៊ំ?

បិៈ នៅកងរួច គេរំសាយឲ្យធ្វើស្រែ ខ្ញុំធ្វើស្រែរួចក៏ខ្ញុំរត់ ខ្ញុំរត់ឡើង១ឆ្នាំជាង ។

អ្នកជិតខាងៈ រត់ទៅណា? រត់មកនេះ?

បិៈ ទេ រត់ប្រុងទៅថៃ តែទៅមិនរួច ដល់នេះទៅរដ្ឋកម្ពុជាគេរំដោះយួនចូលមកដល់ស្វាយ ពួកខ្ញុំរត់ទៅស្វាយ ។

ប៊ុនថន ៖ អ៊ំមកធ្វើនៅអាងថ្កាំនេះធ្វើទាល់តែដល់៧៩តែម្តង?

បិៈ មិនទេ ព្រោះខ្ញុំទៅកាលឆ្នាំ៧៦នោះ ៧៧ខ្ញុំរត់អស់ទៅ ខ្ញុំរត់ប្រុងទៅថៃតែវាមិនរួច ខ្ញុំព័ទ្ធតាមព្រឹទ្ធតាមព្រៃ ដល់រដ្ឋកម្ពុជារំដោះមកខ្ញុំរត់ទៅស្វាយ រត់ទៅបានគេរើសពួកខ្ញុំធ្វើជាគិញ ពួកវៀតណាមទេរើសពួកខ្ញុំធ្វើជាគិញ បានអូសទាញពួកវៀតណាមឡើងមកវៃតាម បារាយណ៍ តាមក្បាលគគីរ ។

ប៊ុនថន ៖ អ៊ំម៉េចបានរត់ចេញពី ប្រុងរត់ចេញទៅថៃ?

បិៈ មិនរត់ឯណាបើគឹង បើមើលទៅសភាពការណ៍មិនស្រួល ។

ប៊ុនថន ៖ គឹងយ៉ាងម៉េចវិញអ៊ំ?

បិៈ គឹងខ្លាចគេវៃចោល ខ្ញុំមិនហ៊ាននៅមើលទៅដូច...ប្រទេសជាតិអីចឹងឯង មកធ្វើការអត់ទាន់ពេលមិនសូវទុកដែរ ។

ប៊ុនថន ៖ ប៉ុន្តែមានអ្នកដែលអ៊ំឃើញហើយ មានអ្នកដែលខ្មែរក្រហមចាប់មានអី បានអ៊ំរត់ទៅ?

បិៈ ខ្ញុំមើលគេរកខ្ញុំដែរ រកឲ្យតែ.....។

ប៊ុនថន ៖ មូលហេតុបានគេ?

បិៈ បងខ្ញុំពីសម័យ គានល់ សុទ្ធតែធ្វើការ បងខ្ញុំដល់ពេលធ្វើការគ្រប់សម័យប្រវត្តិរូបខ្ញុំវាមិន ស្អាត បងខ្ញុំធ្វើការជាខ្លាំង។

ប៊ុនថន ៖ គាត់ធ្វើអីវិញ?

បិៈ គាត់ធ្វើខាងប្រធានភូមិ គាត់មកម៉ិញ នូ ហាន ខ្លាចគេស្រាវជ្រាវប្រវត្តិឃើញ បងខ្ញុំនឹកឃើញមិនសូវស្អាត ខ្ញុំរត់នេះ រត់ទាំងបងខ្ញុំ ទាំងខ្ញុំ តែបងខ្ញុំស្លាប់ហើយ គេឃើញ ខនបាញ់ ខាងជើងធិបតី។

ប៊ុនថន ៖ អីចឹងគេស៊ើបឃើញប្រវត្តិរូបអ៊ំ គេតាមអ៊ំ?

បិៈ បាទ!

ប៊ុនថន ៖ តាមចាប់ហ្នឹង តាមចាប់នៅណាវិញ នៅអាងផ្គាំហ្នឹង?

បិៈ តាមចាប់កាលហ្នឹងគេរំសាយឲ្យមកតាមភូមិ ដល់គេស្រាវជ្រាវទៅ ទៅច្រូតខ្ញុំនៅជិតរលួត ហើយគេចាប់ ហើយបងខ្ញុំប្រវត្តិរូបមិនសូវស្អាតផង ខ្ញុំបងប្អូនគាត់ ហើយមានណាគេអ្នកបងប្អូនគេច្រើនណាស់ក្នុងភូមិ មនុស្សប្រុងរត់ បានវាបែកការណ៍រឿងខ្ញុំ ខ្ញុំរត់ចេញរត់ទៅដែលសល់នៅ ពួកខ្ញុំ៨នាក់នៅសល់២នាក់ ខ្ញុំអស់២នាក់ហើយងាប់ដោយជំងឺទេចូលមកភូមិហើយសម័យរដ្ឋកម្ពុជាហើយ ខ្ញុំអស់២នាក់។

ប៊ុនថន ៖ អីចឹងរត់ចេញទៅច្រើនទេអ៊ំ?

បិៈ ចេញច្រើនណាស់ ឆ្លងមិនផុត សម័យកាលនោះតឹងដែរ ចេញដល់ស្រង៉ែនោះកាលនោះខ្មែរក្រហមវាឡើងទៅឲ្យស្រង៉ែ ដល់ខ្មែរឡើងទៅវាចោទថាខ្មែរក្រហម ពេលខ្មែរឡើងទៅវាបោកខ្មែរយកទៅបាញ់ចោល។

ប៊ុនថន ៖ ខាងថៃ?

បិៈ ខាងថៃ ខាង លន់ នល់ ពួកអន្តរជាតិវាចុះមកជួយសង្គ្រោះអស់មិនតិចទេ ស្រង៉ែពួកភូមិខ្ញុំហ្នឹងឯងទៅមុន។

ប៊ុនថន ៖ អីចឹងនៅហ្នឹងឲ្យតែម៉េចបានថៃនិយាយថាបាញ់ យើងប្រជាជនស៊ីវិលធម្មតា?

បិៈ វាសួរចម្លើយ បើយើងឆ្លើយត្រូវរស់ បើយើងឆ្លើយមិនត្រូវស្លាប់ ពួកប៉ិ គុណ នោះក៏ងាប់ រត់ទៅដល់ថៃ គេឃើញខ្មោចភ្លាម កប់ត្រឹមក ឲ្យដេកកប់ត្រឹមកសួរចម្លើយសួរត្រូវ មិនត្រូវបាញ់ បាញ់ប្រពន្ធប៉ិ គុណ ហៅប៉ិ ហ៊ឹ រត់មកវិញបានចូលពួកខ្ញុំ

កុំទៅប៉ះដល់ នោះយ៉ាប់ទៀត ឆ្លើយត្រូវបានរស់ ឆ្លើយមិនត្រូវក៏ស្លាប់ ឆ្លើយឯណាបើយើងមិនដឹង ។

ប៊ុនថន ៖ គេសួរសំនួរអីខ្លះអ៊ំមានដឹងទេ?

បិៈ ខ្ញុំមិនដឹងទេ មិនបានសួរគេ ដល់គេរត់មកវិញ សួរម៉ិញសួរពីរឿងសម័យកាលនោះអ៊ីឯង បានបំរើអីៗខ្លះ គេសួរសម្ភាសន៍បើយើងឆ្លើយត្រូវក៏បានរស់ យើងឆ្លើយមិនត្រូវស្លាប់ ។

ប៊ុនថន ៖ បើយើងឆ្លើយថាខ្មែរក្រហមគេ?

បិៈ មិនរស់ទេ ។

ប៊ុនថន ៖ អត់រស់ទេ យ៉ាងម៉េចថៃអត់ត្រូវជាមួយខ្មែរក្រហម?

បិៈ អត់ត្រូវគ្នា ព្រោះខាងនោះស្រងែ ពួកខ្មែរក្រហមទៅវ៉ៃបាន វ៉ៃក៏ឲ្យ ។

ប៊ុនថន ៖ ឲ្យម៉េចវិញ?

បិៈ ឲ្យភូមិ ។

ប៊ុនថន ៖ វ៉ៃភូមិហ្នឹង?

បិៈ ហ៊ឺ វ៉ៃភូមិស្រងែ ។

ប៊ុនថន ៖ ភូមិរបស់ថៃ?

បិៈ ភូមិរបស់ថៃ ។

ប៊ុនថន ៖ ខ្មែរក្រហមវ៉ៃចូល?

បិៈ ហ៊ឺ ខ្មែរក្រហមវាវ៉ៃចូល ហើយវាឲ្យភូមិស្រងែ ។

ប៊ុនថន ៖ ចុះខ្មែរក្រហមដែលចាប់បានអ្នកដែររត់ទៅទេ?

បិៈ ចាប់បាន ប្អូនជ្រាបស្រាប់ហើយ តាមព្រំដែន តាមខ្សែមីននោះ នាំគ្នារត់ទៅមើលទៅ កន្ទង់ខ្មោច មិនដឹងធ្វើម៉េចវាប្តូរស្លាប់ប្តូររស់ មួយគ្រាប់ស្លាប់កុំឲ្យតែគេចាប់បាន ភូមិខ្ញុំរត់ ចោលស្រុក១ឆ្នាំនោះ ពួកខ្ញុំសុទ្ធតែប្តូរស្លាប់ ពួកខ្ញុំ ខោន នេះមួយប្រាប់ញាតិ បើសិនគេ ចាប់បានខ្ញុំអត់ឲ្យចាប់ទេ និយាយពីប្តូរស្លាប់ប្តូររស់ មួយគ្រាប់ស្លាប់ហើយនៅតែគេចាប់បាន

ប៊ុនថន ៖ អ៊ំតាំងចិត្តតែម្តង?

បិៈ តាំងចិត្តគ្នា៤នាក់នោះ ចាប់បានអ្នកណាអ្នកនោះស្លាប់ទៅ អត់មានថាជួយគ្នាទេ គឺរករស់ រៀងខ្លួន ថាមួយគ្រាប់ស្លាប់ហើយនៅតែគេចាប់បាន ចាប់បានគេយកទៅវ៉ៃទំរាំតែគេបាញ់ ចោលមិនស្លាយ បានថាប្រពន្ធនិងប្តីមួយគ្រាប់ស្លាប់ចោល នៅតែគេចាប់បាន សុទ្ធចិត្ត ខ្ញុំនៅរបួសដោយសាររត់ ។

ប៊ុនថន ៖ គេបាញ់ត្រូវអី?

ប៊ិៈ គេបាញ់ត្រូវ ។

ប៊ុនថន ៖ ខាងខ្មែរក្រហម ឬខាងថៃ?

ប៊ិៈ ខ្មែរក្រហម ដែលបាញ់បងខ្ញុំស្លាប់ តាមបាញ់ខ្ញុំទៅវាហុមជិត ដាក់បន្តងបាញ់ ខ្ញុំលើកពូថៅនិយាយទៅវាគេច ...បានពូថៅត្រូវវាហុមចាប់បាន ។

ប៊ុនថន ៖ ប៉ុន្មាននាក់អីតាមចាប់អី?

ប៊ិៈ ច្រើនណាស់ពួកវា វារាស់ភ្នំព្រះ ខ្ញុំនៅភ្នំព្រះ ត្រពាំងស្វាយភូមិគេធ្វើថ្មី ។

ប៊ុនថន ៖ ហៅភូមិអីវិញ?

ប៊ិៈ ភូមិត្រពាំងស្វាយ ។

ប៊ុនថន ៖ ស្រុកអី?

ប៊ិៈ ម៉ិញ តាព្រី ។

ប៊ុនថន ៖ ហើយខ្មែរក្រហមតាមអី?

ប៊ិៈ តាមគេរាស់រក រកពួកខ្ញុំដើរតាមអណ្តូងអីចឹង ខែប្រាំងតែមានភ្លើងឆេះទៅវាក្រញ៉ាមនឹងភ្លើងដើរប៉ុន្មាននាក់ឃើញទាំងអស់ ខ្ញុំប៉ុន្មានដណ្តប់នាក់ ១៩នាក់មិនដឹងទៅរកអន្ទរឯណាបានស៊ីដើរលួចជំឡូងគេ ដល់អ្នកស្រុកគេរាយការណ៍ប្រាប់កងទ័ពខ្មែរក្រហមទៅ គេតាមរាស់រកខ្ញុំ ត្រពាំងស្វាយភូមិគេធ្វើថ្មី ជើងភ្នំខ្ញី បានគេហុមទៅបាញ់បងខ្ញុំ ដល់បាញ់ខ្ញុំគេ.. ខ្ញុំលើកពូថៅ ខ្វះអន្ទុយយាមប៉ុន្តែយាម អាខ្វះរវល់តែដេរខោ ដេរអាវខ្លួនឯងមិនបានទៅ មើលគេអ្នកហុមនោះអី ដល់មកជិតគេបាញ់ប្រុៗរត់ទៅគេហុមជិតអស់លើកពូថៅវាគេច ប្រុៗបាញ់តាមពីក្រោយ ។

ប៊ុនថន ៖ ពេលហ្នឹងចាប់អីអត់បានទេ?

ប៊ិៈ ចាប់មិនបានទេ ។

ប៊ុនថន ៖ ខ្មែរក្រហមរត់យ៉ាងម៉េចទៅ?

ប៊ិៈ ខ្មែរក្រហមគ្រាន់តែគ្រៀកដែលខ្ញុំលើកពូថៅ ។

ប៊ុនថន ៖ តែអីរបួសហើយ?

ប៊ិៈ របួសហើយ តែបងខ្ញុំទេដឹងថាគាត់ស្លាប់នៅកន្លែងហ្នឹង ឬកន្លែងណាបាត់ត្រឹមហ្នឹង ពួកខ្ញុំរត់កន្លែងលាក់អន្ទរត្រង់ណា លែងជួបគ្នាហើយ បាត់ណាបាត់ណី ចាំជួបគ្នាកន្លែងលាក់អន្ទរ

ដល់ជួបគ្នាអស់បាត់តែបងខ្ញុំទេ គ្រប់៣ថ្ងៃរាស់រកមើលបង រកមិនឃើញ បាត់ទល់សព្វថ្ងៃ មិនដឹងគេចាប់បាន ឆាប់បាត់ហើយ បើរស់គង់តែលឺដំណឹង ។

ប៊ុនថន : អ៊ំរត់គេចខ្លួនទៅនៅក្នុងព្រៃរហូតដល់រំដោះ?

បិៈ បាទ! ខ្ញុំរត់នៅតែតាមព្រៃ រហូតទៅខែប្រាំងទៅនៅនោះ ខែវស្សាមកនៅក្បែរៗជុំវិញ ភូមិ ធ្លាក់ដល់ខាងកើតភៀសទៅ ខ្ញុំនៅលួចតែដំឡូងរងគេ គេសុំតែមួយរស់ទេ ខ្ញុំនេះធ្វើ ម៉េច ។

ប៊ុនថន : ច្រើននាក់ទេអ៊ំដែលរត់?

បិៈ ៨នាក់ទេ បែកគ្នា ភូមិគេបែកទៅតាមកកន្លែងភូមិគេទៅ ភូមិខ្ញុំទៅភូមិខ្ញុំ ។

ប៊ុនថន : អត់ហ៊ានចូលមកភូមិវិញទេ?

បិៈ មិនហ៊ានទេ ហ៊ានមកដឹងតែឆាប់ សុខចិត្តប្រថុយមួយគ្រាប់ឆាប់ហើយតែគេចាប់បាន ។

ប៊ុនថន : នៅលួចរបស់របរអីហូបរហូត?

បិៈ បាទ! លួចដំឡូងរងសុំតែមួយរស់ ដល់លឺថាកងទ័ពរដ្ឋកម្ពុជាគេរំដោះចូលមកដល់ស្វាយ ដល់ខេត្តដល់មន្ទីរ ខ្ញុំ...... ជំនាន់នោះក៏កងទ័ពវៀតណាម កាលនោះគេរើសឪពុកខ្ញុំធ្វើ យូគិញ ។

ប៊ុនថន : យូគិច ហ្នឹងធ្វើអីវិញ?

បិៈ ណៃ

ប៊ុនថន : គិញ?

បិៈ ទេ ស្វាយត្រាណៃ ។

ប៊ុនថន : កងស្វាយត្រាណៃ?

បិៈ កងស្វាយត្រាណៃ បើវៀតណាមគេហៅយូគិញ អូសកំលាំងកងទ័ពវៀតណាមមកវៃតាម ទីបន្ទង តាមបុសស្បូវ ស្វាយទីង ខាងបារាយណ៍ .. ខ្ញុំគេហុមបាននឹងបារាយណ៍ម្តង ស្មានតែកងទ័ពវៀតណាមដល់កំពែង ដល់វៀតណាមទៅតិច ខ្ញុំស្មានកងទ័ពវៀតណាមវៃ ខ្មែរក្រហមនៅទីតែ វាឡើងទៅវៃពួកខ្ញុំនៅបារាយណ៍ កងទ័ពវៀតណាមកំពុងតែដាំបាយ ហូប ពួកវៀតណាមដាំឆ្អិនក៏ហៅពួកខ្ញុំទៅហូប កំពុងតែហូបបាយជាមួយវៀតណាម ហូបៗខ្មែរក្រហមវាឡើងទៅពីជើង កងទ័ពវៀតណាមរត់ ម្កាក់តាមា នោះរត់អស់វានៅ តែខ្ញុំម្នាក់ឯងគេហុមបាន ខ្ញុំទៅកាយស្លឹកសាបក្នុងគុម្ពឫស្សី សូរដល់នេះខ្មែរក្រហមវាដើរ

តាមផ្លូវគៀនគុម្ពឫស្សីហ្នឹង ខ្ញុំលើកមិនរួចទេមិនហ៊ានកំរើកទេ ខ្លាចវាឃើញ មាឌធំដឹបង២នាក់ សុទ្ធតែអាការថ្មីជ្រើង... គេអុច..អុចចំប៉ើង អុចស្រូវនៅបារាយណ៍ ។

ប៊ុនថន : ដុតចោល?

បិៈ ដុតចោលខ្ញុំ បានថាដល់នេះទៅវាមកដុតឡើង ខ្ញុំគិចទៅក៏កងយូគិញ ពួកស្វាយត្រាណ ឡើងមករកខ្ញុំ ខ្ញុំលោតចេញពីគុម្ពឫស្សីដល់វាលតែម្នាក់ឯង សំរុកទៅរក គេនោះឃើញ គេហៅ បានគេនាំទៅវិញ ហូបបាយនឹងគាត់២នាក់ ថ្ងៃនោះខ្ញុំថាមិនរស់ទេ គេហុមអស់ ។

ប៊ុនថន : អ៊ំធ្វើស្វាយត្រាណហ្នឹងរហូតមក ឬដូរទៅណាវិញ?

បិៈ ធ្វើស្វាយត្រាណរហូត ចូលមកដល់ភូមិវិញគេឲ្យខ្ញុំធ្វើប្រធានឈ្លបហ្នឹងឯង រដ្ឋកម្ពុជាប្រធានឈ្លបក្នុងភូមិសំរាប់ដឹកនាំបងប្អូនកងទ័ពកម្ពុជា កន្លែងណាដែលសភាពការណ៍មិនស្រួលអីខ្ញុំដឹងភូមិសាស្ត្រ ចេះតែនាំខ្ញុំទៅ ត្រូវទៅភូមិណា កងឈ្លបនោះដឹងភូមិសាស្ត្រ ឧទាហរណ៍ទៅភូមិតាត្រៃចេះ ដើរទៅចំកន្លែងណាៗ ។

ប៊ុនថន : អ៊ំអ្នកនាំទៅ?

បិៈ បាទ! ចប់ពីនោះមកក៏គេឲ្យខ្ញុំធ្វើក្រុម ឲ្យជួយពង្រឹងខាងមេក្រុម ពង្រឹងមេក្រុមឡើងប៉ុន្មានឆ្នាំនោះ ឡើងប្រហែល១០ឆ្នាំ បានគេដំឡើងខ្ញុំធ្វើមេហា បាន៥ឆ្នាំ បានឲ្យខ្ញុំឡើងធ្វើក្តាប់ខាងសមាគម ដល់សព្វថ្ងៃ ។

ប៊ុនថន : សមាគមអីវិញ?

បិៈ សមាគមក្នុងភូមិហ្នឹងឯង រួចពីជីវិតសមាគមមក ខ្ញុំធ្វើបាន៣-៤ឆ្នាំ ផុតពីជីវិតសមាគម គេរើសខ្ញុំធ្វើតាអាចារ្យភូមិ ។

ប៊ុនថន : អ៊ំកាលឈ្លបហ្នឹងដូចខ្មែរក្រហមមានចូលដល់ភូមិទេ?

បិៈ ចូលមកដែរ តែខ្ញុំឲ្យតែចូលមកគេត្រូវការបាយ ខ្ញុំក៏រៀបបាយឲ្យគេទៅ ព្រោះយើងនៅជនបទអីចឹង អះអាងថាមិនឲ្យគេចូលក៏មិនហ៊ានទេ ខ្លាចដែរ ប៉ាំវ៉ាមកគេត្រូវការអង្ករបារី ខ្មែរក្រហមត្រូវការបាយការ៉េ កងទ័ពវៀតណាមមកត្រូវការមាន់ ឬត្រូវការអីចេះតែរកឲ្យ ត្រូវការរទេះជួយទៅរកប្រធានភូមិ ។

ប៊ុនថន : ប៉ុន្តែអ៊ំអត់ដែលដូចថាមានគំរាមពីខាងណាទេ?

បិៈ គ្មានទេ មានតែជួយគេ សព្វថ្ងៃខ្ញុំចេះតែធ្វើល្អ សព្វថ្ងៃគេឲ្យខ្ញុំធ្វើអាចារ្យភូមិ ជួយពង្រឹងប្រធានភូមិក្នុងភូមិ ការជួសជុលផ្លូវដាច់ ជួសជុលផ្លូវតាមភូមិ ។

ប៊ុនថន : សមាគមអីអ៊ំ?

បិៈ		ទេ គេហៅអាចារ្យភូមិ សូត្រមន្ត ខាន់និមន្តលោកមកថ្ងៃ៨...។

ប៊ុនថន ៈ	និមន្តមកធ្វើអីវិញអ៊ំ? រើលុយដើម្បីកសាងផ្លូវ?

បិៈ		បាទ! នេះជួសជុលផ្លូវកន្លែងណាដាច់ កន្លែងណាផុង ព្រោះខ្ញុំជួយប្រធានភូមិ អាចារ្យភូមិ សំរាប់ជួយប្រធានភូមិ ខ្វះខាតដូចថាស្រាបាយបងប្អូនដែលមកជួយធ្វើ ខ្ញុំហ្នឹងឯងជួយដោះស្រាយ ។

ប៊ុនថន ៈ	បានថវិកាមកពីណា?

បិៈ		ថវិការពេលថ្ងៃដាច់ ថ្ងៃ៨ដែលបងប្អូនទៅចូលសធា បង្សុកូលក៏ដោយជូនមាតាបិតា បានថវិការហ្នឹងឯងសន្សំទុកសំរាប់ដោះស្រាយ បងប្អូនកសាងផ្លូវតិចតួចជួសជុល ។

ប៊ុនថន ៈ	ឥលូវអ៊ំកូនប៉ុន្មាននាក់ហើយ?

បិៈ		កូនខ្ញុំ៧នាក់ ប្រុស៤ ស្រី៣ ។

ប៊ុនថន ៈ	ហើយបានរៀន មានគ្រួសារអីប៉ុន្មាននាក់?

បិៈ		កូនខ្ញុំអាប្រុសនោះបាន..សព្វថ្ងៃនៅ៣នាក់កូនប្រុសខ្ញុំ ។

ប៊ុនថន ៈ	ប៉ុន្តែមានគ្រួសារអស់ខ្លះហើយ?

បិៈ		នៅមីបងក៏នៅ ដឹកស្រូវ ។

ប៊ុនថន ៈ	ប៉ុន្តែមានបានអី?

បិៈ		រៀន កូនខ្ញុំរៀនបានថ្នាក់ទី៩ ប្រុសបានពីរនាក់ ស្រីពីរក្រោយនោះ មីមួយរៀនថ្នាក់ទី៨ មួយរៀនថ្នាក់ទី៦ ។

ប៊ុនថន ៈ	ខ្ញុំដូចអត់មានអីសួរអ៊ំទៀតទេ ខ្ញុំអស់សំនួរហើយ អរគុណអ៊ំច្រើន ។

បិៈ		បាទ?

ប៊ុនថន ៈ	អរគុណច្រើន ។

**ចប់**